ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ចំណាត់ថ្នាក់ជាតិ

## ផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា( ច.ជ.វ.ប. ) ឆ្នាំ២០២៤

## Cambodia’s Field of Science and Technology (FOS) Classification, 2024




វិទ្យាស្ថានជាតិស្ថិតិ

ក្រសួងផែនការ

ខែមករា ឆ្នាំ២០២៥

# បុព្វកថា

ការអភិវឌ្ឍវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា គឺជាកិច្ចការចាំបាច់ក្នុងការបង្កើនសន្ទុះនៃការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច សំដៅសម្រេចបាននូវចក្ខុវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជា ក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងចំណូលខ្ពស់នៅឆ្នាំ២០៥០។ កិច្ចការនេះតម្រូវឱ្យមានការវិនិយោគទៅលើធនធានមនុស្ស ធនធានហិរញ្ញវត្ថុ និងធនធានធម្មជាតិ។ ការវិនិយោគនេះទទួលបានប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព លុះត្រារៀបចំឱ្យមានយន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ដែលប្រកបដោយតម្លាភាព និងសុខដុមនីយកម្មក្នុងគោលបំណងធ្វើឱ្យមានការឯកភាពគ្នាក្នុងការកត់ត្រា ការរក្សា ការផ្សព្វផ្សាយ និងការប្រើប្រាស់ទិន្នន័យ វិទ្យាសាស្ត្របច្ចេកវិទ្យា។

ក្នុងន័យនេះដើម្បីបម្រើឱ្យការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ប្រកបដោយសុក្រឹតភាព វិទ្យាស្ថានជាតិស្ថិតិ បានធ្វើបច្ចុប្បន្នភាព "ចំណាត់ថ្នាក់ជាតិ ផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា (Cambodia's Field of Science and Technology Classification)" នេះឡើងវិញសំដៅសម្រួលដល់ការប្រមូលទិន្នន័យ ពិសេសពីស្ថាប័នដែលទទួលបន្ទុកស្រាវជ្រាវ និងអភិវឌ្ឍន៍ រួមមាន ស្ថាប័នអាជីវកម្មនិងស្រាវជ្រាវរដ្ឋ គ្រឹះស្ថានសិក្សាជាន់ខ្ពស់ សហគ្រាសអាជីវកម្ម។ មិនតែប៉ុណ្ណោះ ទិន្នន័យនេះនឹងជួយសម្រួលការងាររបស់ក្រសួង ស្ថាប័នពាក់ព័ន្ធដែលទទួលបន្ទុកកិច្ចការគ្រប់គ្រង ជំរុញ និងសម្របសម្រួលការអភិវឌ្ឍវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ផងដែរ។ ទិន្នន័យទាំងអស់ត្រូវបានធ្វើបច្ចុប្បន្នភាពតាមរយៈកិច្ចប្រជុំពិគ្រោះយោបល់របស់ក្រុមការងារបច្ចេកទេស នៃវិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ ដោយមានការចូលរួមពីតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ និងវិស័យឯកជន និងឆ្លងកិច្ចប្រជុំនៃក្រុមប្រឹក្សាស្ថិតិ។

តាងនាមឱ្យក្រសួងផែនការ ខ្ញុំសូមសម្តែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅចំពោះរាជរដ្ឋាភិបាលកម្ពុជា ក្នុងការផ្តល់ការគាំទ្រយ៉ាងពេញទំហឹង ជំរុញឱ្យការងារនេះសម្រេចបានលទ្ធផលគួរជាទីមោទនៈ។ ជាមួយគ្នានេះខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅផងដែរចំពោះ ក្រសួង ស្ថាប័នពាក់ព័ន្ធ និងវិស័យឯកជន ដែលបានផ្តល់ការសហការ និងជំរុញការងារនេះឱ្យកាន់តែមានលក្ខណៈគ្រប់ជ្រុងជ្រោយ ទូលំទូលាយ និងសុក្រឹត។ ជាពិសេសលទ្ធផលដ៏ប្រសើរនេះអាចសម្រេចបានដោយមានការចូលរួមពីថ្នាក់ដឹកនាំ និងមន្ត្រីជំនាញនៃវិទ្យាស្ថានជាតិស្ថិតិ ដែលខិតខំព្យាយាមបំពេញភារកិច្ចយ៉ាងសកម្ម និងហ្មត់ចត់ រហូតដល់ការងារនេះសម្រេចបានភាពជោគជ័យ។

ខ្ញុំសង្ឃឹមយ៉ាងមុតមាំថាគ្រប់ក្រសួង ស្ថាប័នជាតិ អន្តរជាតិនានា អ្នកសិក្សាស្រាវជ្រាវ និងសាធារណជននឹងទទួលបានអត្ថប្រយោជន៍ពីទិន្នន័យនេះ៕

**រដ្ឋមន្ត្រី**

**ប៊ិន ត្រឈៃ**

ក្រសួងផែនការ

រាជធានីភ្នំពេញ

ខែមករា ឆ្នាំ២០២៥

# អារម្ភកថា

វិទ្យាស្ថានជាតិស្ថិតិ បានធ្វើបច្ចុប្បន្នភាពចំណាត់ថ្នាក់ជាតិ ផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា (Cambodia's Field of Science and Technology Classification) នេះឡើងវិញ ដើម្បីឆ្លើយតបទៅនឹងតម្រូវការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការវិនិយោគលើការអភិវឌ្ឍវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ឱ្យបានសុក្រឹត និងឯកភាពគ្នាក្នុងកម្រិតជាតិ និងអាចប្រៀបធៀបគ្នាបានក្នុងកម្រិតតំបន់។ ក្នុងគោលដៅនេះ វិទ្យាស្ថានជាតិស្ថិតិ បានជ្រើសរើសយកចំណាត់ថ្នាក់យោងតាម "អង្គការសម្រាប់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងការអភិវឌ្ឍ" (Organisation for Economic Co-operation and Development (OECD)) ដែលមានប្រទេសជាសមាជិកចំនួន ៣៥ និងបានបង្កើតឡើងនៅឆ្នាំ១៩៦០ ក្នុងគោលបំណង ដើម្បីជំរុញវឌ្ឍនភាពសេដ្ឋកិច្ច និងពាណិជ្ជកម្មពិភពលោក។ ចំណាត់ថ្នាក់ផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា នៃ OECD ដែលត្រូវបានប្រើប្រាស់ដោយអង្គការ UNESCO ផងដែរ បច្ចុប្បន្នមានពីរកម្រិត មានគុណសម្បត្តិគ្រប់គ្រាន់សម្រាប់ការរៀបចំព័ត៌មានស្ថិតិបម្រើឱ្យកិច្ចការគ្រប់គ្រងកម្រិតម៉ាក្រូ។ ទោះជាយ៉ាងណាក្តី ចំណាត់ថ្នាក់របស់ OECD នេះមិនអាចឆ្លើយតបនឹងតម្រូវការកត់ត្រា កិច្ចការអនុវត្ត ជាក់ស្តែងផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ពិសេសនៅមូលដ្ឋាននៃការស្រាវជ្រាវ និងអភិវឌ្ឍន៍ មិនអាចឆ្លើយតបនឹងតម្រូវការព័ត៌មានកម្រិតមីក្រូបានទេ។ ក្នុងកាលៈទេសៈដែលការចែករំលែកព័ត៌មានផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យានៃបណ្តាប្រទេសក្នុងសកលលោកនៅមានកម្រិត ហើយថែមទាំងត្រូវបានចាត់ទុកថាជាព័ត៌មានសម្ងាត់របស់ប្រទេសនីមួយៗ ជម្រើសដែលវិទ្យាស្ថានជាតិស្ថិតិមាន គឺប្រើប្រាស់ប្រព័ន្ធចំណាត់ថ្នាក់ការស្រាវជ្រាវ និងអភិវឌ្ឍន៍ របស់ប្រទេសម៉ាឡេស៊ី ជំនាន់ទី៦ ឆ្នាំ២០១១ និងចំណាត់ថ្នាក់ការស្រាវជ្រាវស្តង់ដាររបស់ប្រទេសអូស្ត្រាលី និងប្រទេសណូវែលហ្សេឡង់ ឆ្នាំ២០០៨ (Australian and New Zealand Standard Research Classification (ANZSRC), 2008) ដើម្បីបំពេញបន្ថែម សម្រាប់តម្រូវការចំពោះមុខរបស់ប្រទេសកម្ពុជា។

សម្រាប់កិច្ចការបរិយាប័ន្ន ចំណាត់ថ្នាក់ជាតិ ផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា នេះ បានដាក់ឆ្លងក្រុមប្រឹក្សាស្ថិតិ។ សម្រាប់កិច្ចខិតខំប្រឹងប្រែងទាំងអស់នេះ ក្នុងនាមវិទ្យាស្ថានជាតិស្ថិតិ ខ្ញុំសូមថ្លែងអំណរគុណជាអនេកជូនចំពោះ **ឯកឧត្តម ប៊ិន ត្រាឈៃ រដ្ឋមន្ត្រីក្រសួងផែនការ** និងជូនដល់ក្រសួង ស្ថាប័ន និងផ្នែកដែលពាក់ព័ន្ធបានគាំទ្រ និងរួមចំណែកអស់ពីលទ្ធភាពដល់កិច្ចការធ្វើបច្ចុប្បន្នភាពចំណាត់ថ្នាក់ជាតិ ផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា។

ខ្ញុំសង្ឃឹមនិងជឿជាក់ថា ចំណាត់ថ្នាក់ជាតិ ផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យានេះនឹងបានជាមូលដ្ឋានសម្រាប់បម្រើឱ្យការប្រមូល ការរក្សាទិន្នន័យ ការផ្សព្វផ្សាយ និងប្រើប្រាស់ព័ត៌មានវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាឱ្យមានការឯកភាពគ្នា ដើម្បីកិច្ចការរៀបចំផែនការ គោលនយោបាយ ការសម្រេចចិត្ត និងការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ កិច្ចការអភិវឌ្ឍវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ឱ្យមានប្រសិទ្ធភាព៕

**អគ្គនាយកវិទ្យាស្ថានជាតិស្ថិតិ**

**ទ្រី ឬទ្ធា**

# មាតិកា

ទំព័រ


បុព្វកថា ..... i

អារម្ភកថា ..... ii

មាតិកា ..... iii

វាក្យសព្ទ ..... ១

១ សេចក្តីផ្តើម ..... ៥

២ គោលបំណងនៃចំណាត់ថ្នាក់ជាតិផ្នែកវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា ..... ៥

៣ វិសាលភាពនៃចំណាត់ថ្នាក់ជាតិ ផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ..... ៥

៤ រចនាសម្ព័ន្ធនៃចំណាត់ថ្នាក់ជាតិ ផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ..... ៨

៥ ការប្រើប្រាស់ចំណាត់ថ្នាក់ជាតិ ផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ..... ៩

៦ ចំណាត់ថ្នាក់ជាតិ ផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា នៃផ្នែក និងក្រុម ទាំងអស់ ..... ១០

៧ ចំណាត់ថ្នាក់ជាតិ ផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា នៃក្រុម និងថ្នាក់ ទាំងអស់ ..... ១៣

ផ្នែក១ ៖ វិទ្យាសាស្ត្រធម្មជាតិ ..... ២៥

ផ្នែក២ ៖ វិស្វកម្ម និងបច្ចេកវិទ្យា ..... ៤៩

ផ្នែក៣ ៖ វិទ្យាសាស្ត្រវេជ្ជសាស្ត្រ និងសុខាភិបាល ..... ៦៧

ផ្នែក៤ ៖ វិទ្យាសាស្ត្រកសិកម្ម ..... ៨១

ផ្នែក៥ ៖ វិទ្យាសាស្ត្រសង្គម ..... ៩៣

ផ្នែក៦ ៖ មនុស្សសាស្ត្រ ..... ១១១

ឯកសារយោង

# វាក្យសព្ទ[1]

**វិទ្យាសាស្ត្រ** (science) ៖ សំដៅដល់ចំណេះដឹងអំពីធម្មជាតិ។

**បច្ចេកវិទ្យា** (technology) ៖ ការប្រើប្រាស់ចំណេះដឹងអំពីធម្មជាតិសម្រាប់ជាប្រយោជន៍របស់មនុស្សជាតិ។

**នវានុវត្តន៍** (innovation) ៖ ការអនុវត្តផលិតផល (ទំនិញឬសេវា) ឬវិធីសាស្ត្រដែលថ្មី ឬត្រូវបានកែលម្អប្រសើរជាងមុនគួរឱ្យកត់សម្គាល់។

**ការស្រាវជ្រាវ និងអភិវឌ្ឍន៍** (scientific research and experimental development or research and development or R&D) ៖ សំដៅដល់សកម្មភាពស្នូលនៃវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា។ ការងារប្រកបដោយការច្នៃប្រឌិត និងមានលក្ខណៈជាប្រព័ន្ធ ផ្អែកលើចំណេះដឹងដែលមាន ដើម្បីបង្កើតថ្មីធ្វើឱ្យប្រសើរឡើង និងបង្កើននូវសន្និធិនៃចំណេះដឹងសម្រាប់មនុស្សជាតិ។ ការស្រាវជ្រាវនិងអភិវឌ្ឍន៍មានបីប្រភេទ ឬតំណាក់កាល៖ ១) ការស្រាវជ្រាវបឋម (basic research) ២) ការស្រាវជ្រាវអនុវត្តន៍ (applied research) និង៣) ការអភិវឌ្ឍដោយពិសោធន៍ (experimental development)។

**ការស្រាវជ្រាវបឋម** (basic/pure research) ៖ សំដៅដល់ការស្រាវជ្រាវ និងការពិសោធវិទ្យាសាស្ត្រសំដៅរៀបចំទ្រឹស្តី និងក្បួនខ្នាតដែលត្រូវបានអនុវត្តជាចម្បងដើម្បីពន្យល់ ឬព្យាករណ៍បាតុភូតធម្មជាតិ និងទិដ្ឋភាពសច្ចភាព ដោយមិនបានគិតអំពីការប្រើប្រាស់ចំណេះដឹងនេះដើម្បីដោះស្រាយបញ្ហាជាក់ស្តែងនោះទេ។

**ការស្រាវជ្រាវអនុវត្តន៍** (applied research) ៖ សំដៅដល់ការស្រាវជ្រាវ និងការពិសោធដោយប្រើប្រាស់វិធីសាស្ត្រដែលមានលក្ខណៈវិទ្យាសាស្ត្រ ក្នុងគោលបំណងចម្បងគឺដើម្បីទទួលបាននូវចំណេះដឹងថ្មីៗ បច្ចេកវិទ្យា ឬបច្ចេកទេសសម្រាប់ការប្រើប្រាស់ដើម្បីដោះស្រាយបញ្ហាជាក់ស្តែងណាមួយ។

**ការអភិវឌ្ឍដោយពិសោធន៍** (experimental development) ៖ សំដៅដល់ការស្រាវជ្រាវ និងការពិសោធមានលក្ខណៈជាប្រព័ន្ធ សំដៅដល់ការបង្កើតផលិតផលថ្មី វិទ្យាសាស្ត្រថ្មី សេវាកម្មថ្មី សង្វាក់ផលិតកម្មថ្មី ឬការធ្វើឱ្យកាន់តែប្រសើរឡើងនូវសង្វាក់ផលិតកម្មដែលមានស្រាប់ ដោយប្រើប្រាស់នូវចំណេះដឹង ដែលទទួលបានពីការស្រាវជ្រាវ និងបទពិសោធវិទ្យាសាស្ត្រ។

**សកម្មភាពដែលមិនត្រូវបានចាត់ទុកជាការស្រាវជ្រាវ និងអភិវឌ្ឍន៍៖**

- ការផ្តល់ប្រឹក្សា។
- ការអប់រំ និងការបណ្តុះបណ្តាល។ ដោយឡែក ការស្រាវជ្រាវដោយនិស្សិតថ្នាក់បណ្ឌិតនៅសាកលវិទ្យាល័យ ត្រូវបានចាត់ទុកជាការស្រាវជ្រាវនិងអភិវឌ្ឍន៍ តាមការគួរ។

[1] វាក្យសព្ទទាំងនេះបានផ្អែកជាចម្បងលើឯកសាររបស់ អង្គការសម្រាប់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងការអភិវឌ្ឍ (Organization for Economic Cooperation and Development ឬ OECD)។

- ការប្រមូលទិន្នន័យជាប្រចាំ សម្រាប់គោលបំណងទូទៅ។
- ការសិក្សាទីផ្សារ។
- ការសាកល្បង ឬការពិសោធន៍ ជាប្រចាំ។
- ការសិក្សាពីលទ្ធភាព ដូចជា ការសិក្សាស្រាវជ្រាវពីគម្រោងវិស្វកម្មដោយប្រើប្រាស់បច្ចេកទេសដែលមានស្រាប់ (លើកលែងតែវាជាចំណែកនៃការស្រាវជ្រាវនិងអភិវឌ្ឍន៍)។
- ការសិក្សាស្រាវជ្រាវជាប្រចាំនៃវេជ្ជសាស្ត្រជំនាញ ឧទាហរណ៍ ការធ្វើរោគវិនិច្ឆ័យជាអាទិ៍។
- កិច្ចការរដ្ឋបាល និងកិច្ចការច្បាប់ពាក់ព័ន្ធនឹងការផ្តល់ប្រកាសនីយបត្រតក្កកម្ម(patent) និងអាជ្ញាប័ណ្ណ។ ដោយឡែកកិច្ចការដែលទាក់ទងផ្ទាល់នឹងការទទួលប្រកាសនីយបត្រតក្កកម្ម នៃការស្រាវជ្រាវនិងអភិវឌ្ឍន៍ ត្រូវបានរាប់បញ្ចូលជាការស្រាវជ្រាវនិងអភិវឌ្ឍន៍។
- សកម្មភាពដែលពាក់ព័ន្ធនឹងកម្មវិធីកំព្យូទ័រ ដែលមានលក្ខណៈជាប្រចាំ។

**បុគ្គលិក/កម្លាំងពលកម្ម ផ្នែកការស្រាវជ្រាវ និងអភិវឌ្ឍន៍៖** អ្នកដែលធ្វើការឱ្យការស្រាវជ្រាវនិងអភិវឌ្ឍន៍ដោយផ្ទាល់ទាំងអស់ (សំខាន់គឺ អ្នកស្រាវជ្រាវ អ្នកបច្ចេកទេស និងបុគ្គលិកគាំទ្រ) និងអ្នកដែលផ្តល់សេវាផ្ទាល់ដល់សកម្មភាព R&D (ដូចជា អ្នកគ្រប់គ្រង អភិបាលរដ្ឋបាល ស្មៀន សម្រាប់ការងារការស្រាវជ្រាវនិងអភិវឌ្ឍន៍) ដោយចូលរួមយ៉ាងតិចណាស់ ៥% នៃពេលវេលាធ្វើការងាររបស់ពួកគាត់។ ចំពោះអ្នកដែលផ្តល់សេវាមិនផ្ទាល់ ដូចជា បុគ្គលិកអាហារដ្ឋាន និងបុគ្គលិកសន្តិសុខ មិនត្រូវបានរាប់បញ្ចូលទេ។

**អ្នកស្រាវជ្រាវ (researcher) ៖** ជាអ្នកជំនាញអាជីព ដែលផ្តល់ទស្សនទាន ឬបង្កើតចំណេះដឹងថ្មី ផលិតផលថ្មី យន្តការថ្មី វិធីសាស្ត្រថ្មី និងប្រព័ន្ធថ្មី និងអ្នកដែលចូលរួមចាត់ចែងគម្រោង នៃ ការស្រាវជ្រាវនិងអភិវឌ្ឍន៍ ដែលពាក់ព័ន្ធ។ ពួកគាត់ជា អ្នកវិទ្យាសាស្ត្រ វិស្វករ និងគ្រូបង្រៀន។

ត្រូវបានរាប់បញ្ចូលជាអ្នកស្រាវជ្រាវផងដែរចំពោះ អ្នកគ្រប់គ្រង និងអភិបាលរដ្ឋបាល ដែលចូលរួមការរៀបចំផែនការ និងការគ្រប់គ្រង ផ្នែកវិទ្យាសាស្ត្រ និងបច្ចេកទេស នៃការងាររបស់អ្នកស្រាវជ្រាវ។ ជាធម្មតា ឋានៈរបស់គាត់ស្មើ ឬខ្ពស់ជាងអ្នកស្រាវជ្រាវ ហើយជារឿយៗ គាត់គឺជាអតីតអ្នកស្រាវជ្រាវ ឬបច្ចុប្បន្នជាអ្នកស្រាវជ្រាវក្រៅម៉ោង។

មិនត្រូវបានរាប់បញ្ចូលជាអ្នកស្រាវជ្រាវទេចំពោះអ្នកគ្រប់គ្រង និងនាយកទាំងឡាយណាដែលជាប់ពាក់ព័ន្ធជាសំខាន់ជាមួយនឹងការងារថវិកា និងធនធានមនុស្សជាងការគ្រប់គ្រង ឬការងារស្នូលរបស់គម្រោងការស្រាវជ្រាវនិងអភិវឌ្ឍន៍ (រាប់បញ្ចូលនៅក្នុងផ្នែក "បុគ្គលិកដទៃទៀតដែលគាំទ្រដោយផ្ទាល់ដល់ R&D")។

**នៅក្នុងវិស័យអប់រំជាន់ខ្ពស់ អ្នកស្រាវជ្រាវមានដូចខាងក្រោម៖**

ក) បុគ្គលិកសិក្សាដែលចូលរួម និងចាត់ចែងការស្រាវជ្រាវ។

ខ) និស្សិតកម្រិតអនុបណ្ឌិត ឬបណ្ឌិតជាជំនួយការការងារស្រាវជ្រាវ។

គ) និស្សិតកំពុងសិក្សាកម្រិតក្រោយបណ្ឌិតទាំងអស់ ដែលស្ថាប័នបានប្រគល់ភារកិច្ចស្រាវជ្រាវជូន។

**អ្នកបច្ចេកទេស** (technician) ៖ អ្នកដែលធ្វើការងារបច្ចេកទេសដើម្បីគាំទ្រដល់ការស្រាវជ្រាវនិងអភិវឌ្ឍន៍ ហើយជាធម្មតាស្ថិតនៅក្រោមការដឹកនាំ និងការត្រួតពិនិត្យផ្ទាល់របស់អ្នកស្រាវជ្រាវ។

**បុគ្គលិកគាំទ្រ** (supporting staff) ៖ សិប្បករជំនាញនិងមិនជំនាញ លេខាធិការ និងស្មៀន ដែលចូលរួមដោយផ្ទាល់ ឬផ្តល់សេវាកម្មដល់អ្នកស្រាវជ្រាវក្នុងគម្រោងស្រាវជ្រាវនិងអភិវឌ្ឍ។ ត្រូវបានរាប់បញ្ចូលផងដែរនូវអ្នកគ្រប់គ្រង និងនាយកទាំងឡាយណាដែលជាប់ពាក់ព័ន្ធជាសំខាន់ជាមួយនឹងការងារថវិកា និងធនធានមនុស្សក្នុងការគាំទ្រដល់កិច្ចការស្រាវជ្រាវជាងការគ្រប់គ្រងបច្ចេកទេសនៃគម្រោងស្រាវជ្រាវដោយផ្ទាល់។

**ចំនួនរាប់** (headcount) ៖ ចំនួនសរុបនៃបុគ្គលិកដែលជាប់ពាក់ព័ន្ធនឹងការស្រាវជ្រាវនិងអភិវឌ្ឍន៍ទាំងអស់ ដោយរួមបញ្ចូលទាំងបុគ្គលិកពេញម៉ោង និងបុគ្គលិកក្រៅម៉ោង។

**សមមូលនៃរយៈពេលពេញម៉ោង** (full-time equivalent (FTE)) ៖ ឯកតារង្វាស់នៃបុគ្គលិក/កម្លាំងពលកម្ម ផ្នែកការស្រាវជ្រាវនិងអភិវឌ្ឍន៍។ សមមូលនៃរយៈពេលពេញម៉ោង (FTE) មួយ អាចត្រូវបានចាត់ទុកថាជាកម្លាំងពលកម្មមួយឆ្នាំពេញនៃមនុស្សម្នាក់។ ដូចនេះ មនុស្សម្នាក់ដែលជាធម្មតាចំណាយ ៣០% នៃពេលវេលារបស់គាត់ទៅលើការស្រាវជ្រាវនិងអភិវឌ្ឍន៍ និងប្រើពេលដែលនៅសល់សម្រាប់សកម្មភាពផ្សេងទៀត (ដូចជាការបង្រៀន កិច្ចការរដ្ឋបាលរបស់សាកលវិទ្យាល័យ និងការផ្តល់ប្រឹក្សាដល់សិស្ស) ត្រូវបានចាត់ទុកថាស្មើ ០,៣ សមមូលនៃរយៈពេលពេញម៉ោង (FTE) ក្នុងកិច្ចការស្រាវជ្រាវ។ ដូចគ្នានេះដែរ ប្រសិនបើមានពលករធ្វើការពេញម៉ោងក្នុងផ្នែកការស្រាវជ្រាវ និងអភិវឌ្ឍន៍ និងត្រូវបានគេជួលឱ្យធ្វើការសម្រាប់តែរយៈពេលប្រាំមួយខែ នោះការងារសមមូលនៃរយៈពេលពេញម៉ោងនៃការងាររបស់គាត់គឺ ០,៥។ អាស្រ័យដោយថ្ងៃធ្វើការ(រយៈពេលធ្វើការ) ជាធម្មតា អាចខុសគ្នាពីវិស័យមួយទៅវិស័យមួយទៀត និងពីស្ថាប័នមួយទៅស្ថាប័នមួយទៀត វាជាការមិនត្រឹមត្រូវក្នុងការបង្ហាញសមមូលនៃរយៈពេលពេញម៉ោង (FTE) គិតជាម៉ោងនៃពលកម្មទេ។

**ចំណាយក្នុងស្រុកសរុបលើការស្រាវជ្រាវនិងអភិវឌ្ឍន៍** (Gross Domestic Expenditure on R&D or GERD) ៖ ការចំណាយក្នុងស្រុកសរុប (ជាសាច់ប្រាក់ និងការទូទាត់បញ្ជី) លើការស្រាវជ្រាវនិងអភិវឌ្ឍន៍ ជាទូទៅត្រូវបានបង្ហាញជាភាគរយនៃផលិតផលក្នុងស្រុកសរុប(GDP)។ ការគណនាមានរួមបញ្ចូលការចំណាយចរន្ត និងការចំណាយមូលធន ប៉ុន្តែតម្លៃនៃការរំលស់មិនត្រូវបានរាប់បញ្ចូលទេ។

**ចំណាយចរន្ត** (current expenditure) ៖ ចំណាយប្រតិបត្តិការផ្ទៃក្នុងលើទំនិញ (ការទិញឧបករណ៍និងសម្ភារៈ) និងលើសេវាកម្ម (ដូចជាប្រាក់ឈ្នួល និងប្រាក់ខែបុគ្គលិកស្រាវជ្រាវនិងអភិវឌ្ឍន៍) ប្រើប្រាស់នៅក្នុងឆ្នាំបច្ចុប្បន្ន ដែលត្រូវទូទាត់ដើម្បីទ្រទ្រង់ចីរភាពនៃសកម្មភាពស្រាវជ្រាវនិងអភិវឌ្ឍន៍។ ការគណនា ចំណាយចរន្តនេះរួមបញ្ចូលទាំងការចំណាយលើកម្លាំងពលកម្ម និងចំណាយប្រតិបត្តិការ។

**ថ្លៃកម្លាំងពលកម្ម** (labour cost) ៖ ប្រាក់ខែសរុបរបស់អ្នកស្រាវជ្រាវ អ្នកបច្ចេកទេស និងបុគ្គលិកគាំទ្រ (ប្រាក់ខែគោលបូករួមប្រាក់ឧបត្ថម្ភ) គុណនឹងសមមូលនៃរយៈពេលពេញម៉ោង (FTE)។

**ថ្លៃប្រតិបត្តិការ (operating cost)** ៖ ការចំណាយសម្រាប់ដំណើរការ ដើម្បីទ្រទ្រង់សកម្មភាពការស្រាវជ្រាវនិងអភិវឌ្ឍន៍ ដោយផ្តោតជាសំខាន់លើការចំណាយសម្រាប់ការប្រើប្រាស់ ការជួសជុលថែទាំ ឥន្ធនៈ ការទិញសម្ភារ សៀវភៅ ទស្សនាវដ្តី សម្រាប់គោលបំណងការស្រាវជ្រាវនិងអភិវឌ្ឍន៍ ការព្រាងគំរូ ការជាវទិន្នន័យយោងនិងការងារកម្រៃជើងសារ។ ថ្លៃប្រតិបត្តិការក៏រួមបញ្ចូលផងដែរនូវថ្លៃជួលកន្លែង កម្រៃនិងថ្លៃឈ្នួលដែលទំនាក់ទំនងជាមួយការស្រាវជ្រាវនិងអភិវឌ្ឍន៍ ការកែច្នៃទិន្នន័យ និងការបង់ប្រាក់ទៅឱ្យអង្គភាពខាងក្រៅសម្រាប់ការប្រើប្រាស់សម្ភារបរិក្ខារដើម្បីការធ្វើតេស្តឯកទេស។

**ចំណាយមូលធន (capital expenditure)** ៖ ចំណាយសរុបលើអចលនទ្រព្យសម្រាប់អនុវត្តការស្រាវជ្រាវនិងអភិវឌ្ឍន៍ ដូចជាដី អាគារ រចនាសម្ព័ន្ធផ្សេងទៀត (បន្ទប់ពិសោធន៍ រោងចក្រ។ល។) យានយន្ត ផ្នែកទន់ ម៉ាស៊ីន និងបរិក្ខារ។ រួមបញ្ចូលផងដែរនូវតម្លៃគណនានៃចំណែកកន្លែងដែលត្រូវបានប្រើប្រាស់សម្រាប់ការស្រាវជ្រាវ បើទោះបីជាវាមិនត្រូវបានបញ្ចូលជាចំណាយផ្ទាល់របស់ការស្រាវជ្រាវក៏ដោយ។

**ប្រភពមូលនិធិ (source of fund)** ៖ មូលនិធិជាទុនដែលបានទទួលក្នុងទម្រង់ផ្សេងៗ (ដូចជាជំនួយ កិច្ចសន្យា ប្រាក់ខែ កម្រៃជើងសារ និងអំណោយនានា) ដើម្បីផ្តល់ហិរញ្ញវត្ថុសម្រាប់សកម្មភាពការស្រាវជ្រាវនិងអភិវឌ្ឍន៍។ មូលនិធិអាចមានប្រភពពីរដ្ឋាភិបាល វិស័យឯកជន ក្រសួង-ស្ថាប័ននានានៃរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល អង្គការ-ស្ថាប័នអន្តរជាតិ បរទេស មូលនិធិផ្សេងទៀត និងពីស្ថាប័នខ្លួនឯងផ្ទាល់។

**ការធ្វើចំណាត់ថ្នាក់ការស្រាវជ្រាវ និងអភិវឌ្ឍន៍ (R&D Classification)** ៖ សកម្មភាព គោលបំណង និងលទ្ធផលនៃការស្រាវជ្រាវ និងអភិវឌ្ឍន៍ត្រូវបានធ្វើចំណាត់ថ្នាក់តាមវិស័យនៃការស្រាវជ្រាវ (Field of Research (FoR)) និងគោលបំណងសេដ្ឋកិច្ច (Socio-Economic Objective (SEO)) ដោយមានការដាក់លេខកូដផងដែរ។

**ការធ្វើចំណាត់ថ្នាក់តាមផ្នែក (Sector Classification)** ៖ ស្ថាប័នដែលអនុវត្តការស្រាវជ្រាវនិងអភិវឌ្ឍន៍ និងបានចូលរួមផ្តល់ទិន្នន័យនៅក្នុងការអង្កេតនេះត្រូវបានចាត់ថ្នាក់ជាបួនផ្នែកគឺ៖ ១) ស្ថាប័នអាជីវកម្មនិងស្រាវជ្រាវរដ្ឋ ២) គ្រឹះស្ថានសិក្សាជាន់ខ្ពស់ ៣) សហគ្រាសអាជីវកម្ម និង៤) អង្គការមិនមែនរដ្ឋាភិបាល។

១. **ស្ថាប័នអាជីវកម្មនិងស្រាវជ្រាវរដ្ឋ** ៖ ផ្នែកនេះរួមមាន ក្រសួង ស្ថាប័ន និងវិទ្យាស្ថានស្រាវជ្រាវរដ្ឋទាំងអស់។

២. **គ្រឹះស្ថានសិក្សាជាន់ខ្ពស់** ៖ ផ្នែកនេះរួមមានសាកលវិទ្យាល័យ មហាវិទ្យាល័យ សាលាវិជ្ជាជីវៈ សាលាពហុបច្ចេកទេស និងស្ថាប័នអប់រំក្រោយមធ្យមសិក្សាទាំងអស់។ រួមបញ្ចូលផងដែរនូវវិទ្យាស្ថានស្រាវជ្រាវ ស្ថានីយ៍ឬមន្ទីរពិសោធន៍ និងគ្លីនិកក្រោមការគ្រប់គ្រងផ្ទាល់នៃស្ថាប័នទាំងនោះ។

៣. **សហគ្រាសអាជីវកម្ម** ៖ ផ្នែកនេះរួមបញ្ចូលក្រុមហ៊ុនទាំងអស់ អង្គភាពនិងស្ថាប័ននានាដែលមានសកម្មភាពចម្បងគឺផលិតកម្មសម្រាប់ទីផ្សារទំនិញ ឬសេវាកម្ម ដើម្បីលក់ដល់សាធារណៈជនទូទៅ ក្នុងគោលបំណងសំខាន់គឺប្រាក់ចំណេញផ្នែកសេដ្ឋកិច្ច។

៤. **អង្គការមិនមែនរដ្ឋាភិបាល** ៖ អង្គភាពមិនរកប្រាក់ចំណេញ ទទួលបានឯករាជ្យមានកម្រិតពីរដ្ឋ និងអង្គការរដ្ឋាភិបាលអន្តរជាតិ។ ផ្នែកនេះជាធម្មតាត្រូវបានផ្តល់មូលនិធិក្នុងទម្រង់ជាជំនួយ និងការគ្រប់គ្រងចាត់ចែងជាចម្បងដោយអ្នកស្ម័គ្រចិត្ត។

# ចំណាត់ថ្នាក់ជាតិ
# ផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា(ច.ជ.វ.ប.)

## ១. សេចក្ដីផ្ដើម

ដើម្បីឆ្លើយតបនឹងតម្រូវការនៃការកត់ត្រាទិន្នន័យ និងការប្រើប្រាស់ព័ត៌មានផ្នែកវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា ទាំងកម្រិតម៉ាក្រូ និងកម្រិតមីក្រូ វិទ្យាស្ថានជាតិស្ថិតិ បានរៀបចំចំណាត់ថ្នាក់ជាតិ ផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា (ច.ជ.វ.ប.) ឆ្នាំ២០១៧ របស់កម្ពុជានេះជា ៤ កម្រិត គឺ៖ (១)ផ្នែក (២)ក្រុម (៣)ថ្នាក់ និង (៤) ថ្នាក់រង។ ចំណាត់ថ្នាក់ជាតិ ផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ឆ្នាំ២០២៤ នេះ គឺជាចំណាត់ថ្នាក់ជំនាន់ទី២ របស់កម្ពុជា ត្រូវបានរៀបចំសំដៅឆ្លើយតបទៅនឹងតម្រូវការចំពោះមុខ ដើម្បីឱ្យកិច្ចការអភិវឌ្ឍវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាបានប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាព។ នៅក្នុងការអនុវត្តជាក់ស្ដែង និងនៅក្នុងបរិបទដែលការអភិវឌ្ឍវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាមានការវិវឌ្ឍប្រកបដោយលក្ខណៈឌីណាមិក ចំណាត់ថ្នាក់នេះអាចនឹងត្រូវបានស្នើបន្ថែមសកម្មភាព ជាមួយនឹងលេខកូដរបស់សកម្មភាពនោះ ដោយធ្វើយ៉ាងណាឱ្យការបន្ថែមនោះត្រូវបានប្រើប្រាស់រួមគ្នាក្នុងកម្រិតជាតិផង និងស្របទៅនឹងការអនុវត្តជាអន្តជាតិផង។

## ២. គោលបំណងនៃចំណាត់ថ្នាក់ជាតិ ផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា

គោលបំណងចម្បងរបស់ ច.ជ.វ.ប. ឆ្នាំ២០២៤ ជំនាន់ទី២នេះ គឺសម្រាប់ការធ្វើចំណាត់ថ្នាក់ ការពណ៌នា និងការកត់ត្រាសកម្មភាព និងជំនាញ នៃការស្រាវជ្រាវនិងអភិវឌ្ឍន៍នៅកម្ពុជាឱ្យបានលម្អិត និងសុក្រឹតដើម្បីបម្រើឱ្យកិច្ចការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ក៏ដូចជាកិច្ចការរៀបចំគោលនយោបាយ រៀបចំផែនការ ការសម្រេចចិត្ត និងការសិក្សាស្រាវជ្រាវ លើការគ្រប់គ្រងការអភិវឌ្ឍវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ឈានដល់ប្រសិទ្ធភាព និងប្រសិទ្ធផល នៃការវិនិយោគលើការអភិវឌ្ឍវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា។ អាស្រ័យដោយ ច.ជ.វ.ប. ប្រើប្រាស់ចំណាត់ថ្នាក់អន្តរជាតិ និងតំបន់ សូចនាករដែលប្រើចំណាត់ថ្នាក់នេះក៏អាចត្រូវបានប្រើប្រាស់ក្នុងការប្រៀបធៀបជាសកលផងដែរ។

## ៣. វិសាលភាពនៃចំណាត់ថ្នាក់ជាតិ ផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា

នៅក្នុងការអនុវត្តជាក់ស្ដែង សកម្មភាពវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា និងសកម្មភាពជាប់ពាក់ព័ន្ធ ដែលមិនមែនជាការស្រាវជ្រាវនិងអភិវឌ្ឍន៍ (R&D) មិនត្រូវរាប់បញ្ចូលក្នុងកិច្ចការវាស់វែងសកម្មភាព R&D ទេ។ សកម្មភាព R&D និងសកម្មភាពដែលងាយនឹងច្រលំជាមួយនឹងការស្រាវជ្រាវនិងអភិវឌ្ឍន៍មានរាយឈ្មោះ ជាមួយនឹងសេចក្ដីពណ៌នាដូចខាងក្រោម ៖

**ការស្រាវជ្រាវ និងអភិវឌ្ឍន៍** (scientific research and experimental development or research and development (R&D)) ៖ សកម្មភាពស្នូលនៃវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា។ ការងារប្រកបដោយការច្នៃប្រឌិត

និងមានលក្ខណៈជាប្រព័ន្ធ អាចផ្អែកលើចំណេះដឹងដែលមាន ដើម្បីបង្កើតថ្មី ធ្វើឱ្យប្រសើរឡើង និងបង្កើននូវសន្និធិនៃចំណេះដឹង សម្រាប់មនុស្សជាតិ។ ការស្រាវជ្រាវនិងអភិវឌ្ឍន៍មានបីប្រភេទ ឬតំណាក់កាល៖ ១/ការស្រាវជ្រាវបឋម (basic research) ២/ការស្រាវជ្រាវសម្រាប់តម្រូវការ (applied research) និង ៣/ការអភិវឌ្ឍបង្កើតដោយពិសោធន៍ (experimental development)។

- **ការស្រាវជ្រាវបឋម** (basic research)៖ ការងារពិសោធន៍ ឬការរៀបចំទ្រឹស្តីដែលត្រូវបានអនុវត្តជាចម្បង ដើម្បីទទួលបាននូវចំណេះដឹងថ្មីនៃហេតុផលដែលនៅពីក្រោយសច្ចភាពនៃបាតុភូត និងទិដ្ឋភាព ដោយមិនបានគិតអំពីការប្រើប្រាស់នៃចំណេះដឹងនេះជាក់ស្តែងទេ។
- **ការស្រាវជ្រាវសម្រាប់តម្រូវការ** (applied research) ៖ ការស្រាវជ្រាវដើម្បីទទួលបាននូវចំណេះដឹងថ្មី។ ការស្រាវជ្រាវនេះមានគោលបំណងជាចំបង គឺដើម្បីទទួលបានលទ្ធផលសម្រាប់ការប្រើប្រាស់ជាក់ស្តែងណាមួយ។
- **ការអភិវឌ្ឍបង្កើតដោយពិសោធន៍** (experimental development) ៖ ការងារធ្វើដោយប្រើប្រាស់ចំណេះដឹងដែលទទួលបានពីការស្រាវជ្រាវនិងបទពិសោធន៍ជាក់ស្តែង និងមានលក្ខណៈជាប្រព័ន្ធ ដើម្បីបង្កើតចំណេះដឹងបន្ថែម សំដៅផលិតផលិតផលថ្មី ផលិតកម្មថ្មី ឬដើម្បីធ្វើឱ្យប្រសើរឡើងនូវផលិតផល ឬផលិតកម្មដែលមានស្រាប់។

## សកម្មភាពដែលទាយនឹងទ្រខ្សាំជាមួយនឹងការស្រាវជ្រាវ និងអភិវឌ្ឍន៍

### ក. ការអប់រំ និងការបណ្តុះបណ្តាលបុគ្គលិក សិស្ស និងនិស្សិត

សកម្មភាពស្រាវជ្រាវសម្រាប់ថ្នាក់ក្រោយឧត្តមសិក្សា រួមបញ្ចូលទាំងសកម្មភាពត្រួតពិនិត្យការស្រាវជ្រាវទាំងអស់នេះត្រូវបានគេចាត់ទុកថាជាសកម្មភាព R&D។ ការអភិវឌ្ឍវិធីសាស្ត្របង្រៀនថ្មីៗក៏ត្រូវបានចាត់ទុកផងដែរថាជាសកម្មភាព R&D ។ ដោយឡែក ការបង្រៀននិងការបណ្តុះបណ្តាលសិស្សនិស្សិត ដោយប្រើប្រាស់វិធីសាស្ត្រ និងមុខវិជ្ជាដែលបានបង្កើតឡើងហើយ មិនត្រូវបានរាប់បញ្ចូលជាសកម្មភាព R&D ទេ។

### ខ. សេវាព័ត៌មានវិទ្យាសាស្ត្រ និងបច្ចេកទេស ជំនាញ

សេវាព័ត៌មានវិទ្យាសាស្ត្រ និងបច្ចេកទេស ជំនាញ ដែលត្រូវបានអនុវត្តសម្រាប់គាំទ្រសកម្មភាព R&D ត្រូវបានចាត់ទុកថាជា សកម្មភាព R&D។ ឧទាហរណ៍ដូចជា ការប្រមូលទិន្នន័យវិទ្យាសាស្ត្រ ការចុះលេខកូដ ការកត់ត្រា ការធ្វើចំណាត់ថ្នាក់ ការផ្សព្វផ្សាយ ការបកប្រែ ការវិភាគ និងសេវាគន្ថនិទ្ទេស។ សេវាព័ត៌មានវិទ្យាសាស្ត្រ និងបច្ចេកទេស ជំនាញ នេះនឹងត្រូវបានដកចេញពីសកម្មភាព R&D ប្រសិនបើវាត្រូវបានអនុវត្តដាច់ដោយឡែក និងមិនគាំទ្រដល់សកម្មភាព R&D។

### គ. ការប្រមូលទិន្នន័យសម្រាប់គោលបំណងទូទៅ ឬជាប្រចាំ

ការប្រមូលទិន្នន័យដើម្បីការគាំទ្រកិច្ចការ R&D ត្រូវបានរួមបញ្ចូលក្នុងកិច្ចការ R&D។ ដោយឡែក ការប្រមូលទិន្នន័យជាលក្ខណៈធម្មតាទូទៅ ត្រូវបានរួមបញ្ចូលជាកិច្ចការ R&D ទេ។ ជាធម្មតាការងារទាំងនេះ ត្រូវបានអនុវត្តដោយស្ថាប័នរដ្ឋាភិបាល ដើម្បីកត់ត្រាទិន្នន័យជីវប្រវត្តិ ទិន្នន័យសេដ្ឋកិច្ច ឬបាតុភូតសង្គម នៃសាធារជន ឬរាជរដ្ឋាភិបាល។ ឧទាហរណ៍ដូចជា ជំរឿនប្រជាជន ការអង្កេតពីភាពគ្មានការងារធ្វើ ការអង្កេត និងការប្រមូលទិន្នន័យទីតាំងភូមិសាស្ត្រ និងការអង្កេតអំពីបរិស្ថាន ជាដើម។

### ឃ. ការថែទាំស្តង់ដារជាតិ

ការធ្វើតេស្តនិងការវិភាគជាប្រចាំ លើសារធាតុ សមាសភាគរូបធាតុ ផលិតផល ការធ្វើតេស្តដី ការត្រួតពិនិត្យបរិយាកាស ។ល។ ដើម្បីអនុលោមតាមស្តង់ដាមិនត្រូវបានរួមបញ្ចូលជាកិច្ចការ R&D ទេ។

### ង. ការសិក្សាពីលទ្ធភាពអនុវត្ត

ការសិក្សាពីលទ្ធភាពអនុវត្តសម្រាប់គាំទ្រដល់សកម្មភាពនៃស្រាវជ្រាវនិងអភិវឌ្ឍ ត្រូវបានរាប់បញ្ចូលជាR&D។ ដោយឡែក ការសិក្សាពីលទ្ធភាពអនុវត្តដែលពាក់ព័ន្ធនឹងការប្រមូលព័ត៌មានអំពីលក្ខខណ្ឌ ឬស្ថានភាពដែលមានស្រាប់ សម្រាប់ការប្រើប្រាស់នៅក្នុងការធ្វើសេចក្តីសម្រេចចិត្ត ថាតើត្រូវអនុវត្តឬមិនត្រូវអនុវត្តគម្រោងណាមួយ មិនត្រូវបានរាប់បញ្ចូល R&D ទេ។

### ច. ការថែទាំផ្នែកវេជ្ជសាស្ត្រឯកទេស

សកម្មភាពផ្នែកនេះដែលត្រូវបានចាត់ទុកជា R&D រួមមានការអភិវឌ្ឍបែបបទ ឬវិធីព្យាបាលថ្មីៗ រួមទាំងការអភិវឌ្ឍដែលជាប់ទាក់ទងនឹងការថែទាំផ្នែកវេជ្ជសាស្ត្រ និងការពិនិត្យរោគសញ្ញាទំនើប ដែលជាធម្មតាត្រូវបានអនុវត្តដោយមន្ទីរពេទ្យនៅសកលវិទ្យាល័យ។ ដោយឡែក ការធ្វើរោគវិនិច្ឆ័យជាប្រចាំ ឬការអនុវត្តនូវចំណេះដឹង បច្ចេកទេស ឬបរិក្ខារ វេជ្ជសាស្ត្រឯកទេសដែលមានស្រាប់ មិនត្រូវបានរាប់បញ្ចូលជាកិច្ចការ R&D ទេ។

### ឆ. ការសាកល្បងគ្លីនិក

ដំណាក់កាលទី១ ទី២ និង ទី៣ នៃការសាកល្បងគ្លីនិក ត្រូវបានរាប់បញ្ចូលក្នុងសកម្មភាពការស្រាវជ្រាវ និងអភិវឌ្ឍន៍(R&D)។ ការសាកល្បងគ្លីនិកនៅដំណាក់កាលទី៤ មិនត្រូវបានរាប់បញ្ចូលជាកិច្ចការ R&D ទេ លើកលែងតែវាបង្កើតបច្ចេកវិទ្យា វិទ្យាសាស្ត្របន្ថែមទៀត។

### ជ. កិច្ចការប្រកាសនីយបត្រតក្កកម្ម និងអាជ្ញាប័ណ្ណ (patent and license)

កិច្ចការប្រកាសនីយបត្រតក្កកម្ម ដែលជាប់ទាក់ទងដោយផ្ទាល់ទៅនឹងគម្រោង R&D ត្រូវបានរួមបញ្ចូលជាសកម្មភាព R&D។ ដោយឡែក កិច្ចការពាណិជ្ជកម្ម រដ្ឋបាល និងនីតិកម្ម ដែលជាប់ទាក់ទងនឹងការផ្តល់ប្រកាសនីយបត្រតក្កកម្ម សិទ្ធិអ្នកនិពន្ធ និងអាជ្ញាប័ណ្ណ មិនត្រូវបានរាប់បញ្ចូលជាកិច្ចការ R&D ទេ។

### ឈ. ការសិក្សាពាក់ព័ន្ធនឹងគោលនយោបាយ

ព្រំដែនរវាងការសិក្សាពាក់ព័ន្ធនឹងគោលនយោបាយខ្លះ ដែលមានពណ៌នានៅក្នុងសៀវភៅណែនាំ Frascati និងសម្មភាព R&D មានលក្ខណៈស្មុគស្មាញ។

ជារួម ការសិក្សាដើម្បីកំណត់ពីប្រសិទ្ធភាពនៃគោលនយោបាយជាតិជាក់លាក់មួយលើស្ថានភាព សេដ្ឋកិច្ច ឬ សង្គម ឬក្រុមនៃសង្គម មានសារធាតុនៃសកម្មភាពស្រាវជ្រាវនិងអភិវឌ្ឍន៍។ ការសិក្សាអំពីការគ្រប់គ្រង ឬ ការសិក្សាអំពីប្រសិទ្ធភាព ជាប្រចាំមិនត្រូវបានរាប់បញ្ចូលជាកិច្ចការ R&D ទេ។

### ញ. ការសិក្សាអំពីផ្សារ និងម៉ាឃិធីង

ការសិក្សាស្រាវជ្រាវអំពីទីផ្សារ និងការស្ទង់មតិ មិនត្រូវបានរាប់បញ្ចូលជាកិច្ចការ R&D ទេ។

### ដ. ការរុករករ៉ែ

ការអភិវឌ្ឍវិធីសាស្ត្រថ្មី ឬវិធីសាស្ត្រដែលមានការកែលម្អច្រើន ក្នុងការប្រមូលទិន្នន័យ ការកែច្នៃទិន្នន័យ និងការបកស្រាយទិន្នន័យផ្នែកនេះ ត្រូវបានរាប់បញ្ចូលជាកិច្ចការ R&D។ ការអង្កេត វាស់ស្ទង់ ដែលអនុវត្តជាផ្នែកមួយនៃគម្រោងការស្រាវជ្រាវនិងអភិវឌ្ឍន៍ ដើម្បីសង្កេតមើលបាតុភូតភូមិសាស្ត្រត្រូវបានចាត់ទុកផងដែរថាជា R&D។ ដោយឡែក ការរុករករ៉ែដោយប្រើវិធីដែលមានស្រាប់ មិនត្រូវបានរាប់បញ្ចូលជាកិច្ចការ R&D ទេ។

### ឋ. ការបង្កើតគំរូ និងការផលិតសាកល្បង (Prototypes and Pilot Plants)

ជាទូទៅ ការរចនា ការបង្កើត និងការធ្វើតេស្តគំរូសាកល្បង ស្ថិតក្នុងវិសាលភាពនៃ R&D។ ដោយឡែក ការផលិតសាកល្បង និងចតចម្លងសំណាកគំរូផលិតផល ត្រូវបានដកចេញពីសកម្មភាព R&D។

ការបង្កើត និងប្រតិបត្តិការផលិតសាកល្បង គឺជាផ្នែកនៃ R&D ឱ្យតែកិច្ចការទាំងនេះត្រូវបានអនុវត្តដើម្បីទទួលបាននូវបទពិសោធន៍ ឬទិន្នន័យថ្មី សម្រាប់ធ្វើការវាយតម្លៃសម្មតិកម្ម។

ការផលិតសាកល្បងត្រូវបានដកចេញពីR&Dភ្លាមៗ នៅពេលដែលដំណាក់កាលពិសោធន៍ត្រូវបានបញ្ចប់ ឬនៅពេលដែលវាត្រូវបានប្រើដើម្បីផលិតកម្មអាជីវកម្មធម្មតា បើទោះបីជាគេនៅបន្តហៅវាថាជាការផលិតសាកល្បង។ ប្រសិនបើការផលិតសាកល្បងត្រូវបានប្រើសម្រាប់ប្រតិបត្តិការរួមគ្នា (សាកល្បង និងអាជីវកម្ម) គេត្រូវប៉ាន់ស្មានយកតែផ្នែកដែលត្រូវបានប្រើប្រាស់សម្រាប់ការស្រាវជ្រាវ និងអភិវឌ្ឍន៍ ប៉ុណ្ណោះ។

## ៤. រចនាសម្ព័ន្ធនៃចំណាត់ថ្នាក់ជាតិ ផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា

ចំណាត់ថ្នាក់ជាតិ ផ្នែកវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា មានរចនាសម្ពន្ធ័ជាឋានានុក្រម៤ កម្រិត៖ (១) ផ្នែកដែលជាចំណាត់ថ្នាក់កម្រិតខ្ពស់បំផុត (២) ក្រុម (៣) ថ្នាក់ និង(៤) ថ្នាក់រង ដែលជាចំណាត់ថ្នាក់កម្រិតទាប ឬលម្អិតបំផុត។ ផ្នែកចំនួន៦ត្រូវបានកំណត់ ដែលផ្នែកនីមួយៗគ្របដណ្តប់សកម្មភាព ឬជំនាញពាក់ព័ន្ធនឹងការស្រាវជ្រាវនិងអភិវឌ្ឍន៍យ៉ាងទូលំទូលាយ។ ផ្នែកនីមួយៗមានក្រុម ថ្នាក់ និងថ្នាក់រង មួយចំនួន ហើយចំណាត់ថ្នាក់កម្រិតទាបជាងមានលេខកូដផ្តើមដោយលេខកូដនៃចំណាត់ថ្នាក់ខ្ពស់ជាង ពោលគឺ៖

- លេខកូដ**ក្រុម**ផ្ដើមដោយលេខកូដផ្នែករបស់វា
- លេខកូដ**ថ្នាក់**ផ្ដើមដោយលេខកូដក្រុមរបស់វា
- លេខកូដ**ថ្នាក់រង**ផ្ដើមដោយលេខកូដថ្នាក់របស់វា

ដើម្បីសម្រួលដល់ការកត់ត្រា និងការប្រើប្រាស់ទិន្នន័យកម្រិតម៉ាក្រូ ផ្នែក និងក្រុមទាំងអស់ត្រូវបានរៀបចំជាតារាងមួយដោយឡែក។ ចំពោះកម្រិតពាក់កណ្ដាលម៉ាក្រូ ក្រុម និងថ្នាក់ទាំងអស់ក៏ត្រូវបានរៀបចំជាតារាងមួយដោយឡែក។ សម្រាប់ការកត់ត្រា និងការប្រើប្រាស់ទិន្នន័យកម្រិតមីក្រូនៃថ្នាក់ និងថ្នាក់រង ចំណាត់ថ្នាក់ត្រូវបានរៀបចំសម្រាប់ផ្នែកនីមួយៗជាបន្តបន្ទាប់។ ភាសាអង់គ្លេសត្រូវបានរក្សានៅគ្រប់ចំណាត់ថ្នាក់ដើម្បីសម្រួលដល់ការស្វែងយល់ និងប្រើប្រាស់។

ឧទាហរណ៍នៃការធ្វើចំណាត់ថ្នាក់ និងលេខកូដ ពីផ្នែក ដល់ថ្នាក់រង មានដូចខាងក្រោម៖

| ផ្នែក ១ (Division 1) | | | | សេចក្ដីអធិប្បាយ | Decription |
|---|---|---|---|---|---|
| ផ្នែក Division | ក្រុម Group | ថ្នាក់ Class | ថ្នាក់រង Sub-Class | ភាសាខ្មែរ | English |
| 1 | | | | វិទ្យាសាស្ត្រធម្មជាតិ | NATURAL SCIENCES |
| | 101 | | | វិទ្យាសាស្ត្រគណិតវិទ្យា | MATHEMATICAL SCIENCES |
| | | 10101 | | គណិតវិទ្យាពិត | PURE MATHEMATICS |
| | | | 1010101 | ពិជគណិត និងទ្រឹស្ដីចំនួន | Algebra and Number Theory |

## ៥. ការប្រើប្រាស់ចំណាត់ថ្នាក់ជាតិ ផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា

ចំណាត់ថ្នាក់ជាតិ ផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ត្រូវបានរៀបចំដើម្បីឆ្លើយតបនឹងតម្រូវការនៃការធ្វើចំណាត់ថ្នាក់ និងការចុះលេខកូដសកម្មភាព និងជំនាញពាក់ពន្ធ័នឹងការស្រាវជ្រាវនិងអភិវឌ្ឍន៍ ឱ្យមានការឯកភាពគ្នានិងប្រកបដោយឋានានុក្រម។ ការធ្វើចំណាត់ថ្នាក់ និងការចុះលេខកូដ គេអាចចាប់ផ្ដើមដោយពិនិត្យរកពីកម្រិតខ្ពស់ (ផ្នែក) និងចុះទៅកម្រិតក្រោមៗ (ក្រុម ថ្នាក់ ថ្នាក់រង) តាមដែលអាចធ្វើទៅបាន។ ទោះបីជានៅខាងចុងនៃក្រុម ថ្នាក់ និងថ្នាក់រង មានចំណាត់ថ្នាក់ "ផ្សេងទៀត" សម្រាប់ចាប់យកព័ត៌មានដែលមិនទាន់បានធ្វើចំណាត់ថ្នាក់ក្ដី ចំណាត់ថ្នាក់ «ផ្សេងទៀត» នេះគួរត្រូវបានចៀសវាងតាមដែលអាចធ្វើទៅបាន ឬត្រូវស្នើចំណាត់ថ្នាក់បន្ថែម ព្រោះវានឹងបង្ហាញពីភាពមិនច្បាស់លាស់នៃព័ត៌មាន។ ក្នុងការប្រើប្រាស់ទិន្នន័យអាចត្រូវបានសំយោគ(បូកសរុប) ពីកម្រិតទាបជាង មកកម្រិតខ្ពស់ជាង តាមតម្រូវការ។

## ៦. ចំណាត់ថ្នាក់ជាតិ ផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា នៃផ្នែក និងក្រុម ទាំងអស់

| ផ្នែក (Division) | | | ក្រុម (Group) | | |
|---|---|---|---|---|---|
| លេខកូដ (Code) | ភាសាខ្មែរ | English | លេខកូដ (Code) | ភាសាខ្មែរ | English |
| 1 | វិទ្យាសាស្ត្រធម្មជាតិ | Natural Sciences | 101 | វិទ្យាសាស្ត្រគណិតវិទ្យា | Mathematical Sciences |
| | | | 102 | វិទ្យាសាស្ត្រព័ត៌មាន និងកុំព្យូទ័រ | Computer and Information Sciences |
| | | | 103 | វិទ្យាសាស្ត្ររូបវិទ្យា | Physical Sciences |
| | | | 104 | វិទ្យាសាស្ត្រគីមីវិទ្យា | Chemical Sciences |
| | | | 105 | វិទ្យាសាស្ត្រផែនដីវិទ្យា | Earth Sciences |
| | | | 106 | វិទ្យាសាស្ត្រជីវវិទ្យា | Biological Sciences |
| | | | 107 | វិទ្យាសាស្ត្របរិស្ថាន | Environmental Sciences |
| | | | 108 | វិទ្យាសាស្ត្រធម្មជាតិផ្សេងៗទៀត | Other Natural Sciences |
| 2 | វិស្វកម្ម និងបច្ចេកវិទ្យា | Engineering and Technology | 201 | វិស្វកម្មសំណង់ស៊ីវិល | Civil Engineering |
| | | | 202 | វិស្វកម្មអគ្គិសនី វិស្វកម្មអេឡិចត្រូនិក វិស្វកម្មព័ត៌មាន | Electrical Engineering, Electronic Engineering, Information Engineering |
| | | | 203 | វិស្វកម្មមេកានិក | Mechanical Engineering |
| | | | 204 | វិស្វកម្មគីមី | Chemical Engineering |
| | | | 205 | វិស្វកម្មរូបធាតុ | Materials Engineering |
| | | | 206 | វិស្វកម្មវេជ្ជសាស្ត្រ | Medical Engineering |
| | | | 207 | វិស្វកម្មបរិស្ថាន | Environmental Engineering |
| | | | 208 | បច្ចេកវិទ្យាជីវបរិស្ថាន | Environmental Biotechnology |
| | | | 209 | បច្ចេកវិទ្យាជីវឧស្សាហកម្ម | Industrial Biotechnology |
| | | | 210 | បច្ចេកវិទ្យាណាណូ | Nano-Technology |
| | | | 211 | វិស្វកម្មអវកាស | Aerospace Engineering |

| | | | | | |
|---|---|---|---|---|---|
| | | | 212 | វិស្វកម្មយានយន្ត | Automotive Engineering |
| | | | 213 | វិស្វកម្មជីវវេជ្ជសាស្ត្រ | Biomedical Engineering |
| | | | 214 | វិស្វកម្មចំណីអាហារ | Food Engineering |
| | | | 215 | វិស្វកម្មមាត្រសាស្ត្រ | Geomatic Engineering |
| | | | 216 | វិស្វកម្មកម្មន្តសាល | Manufacturing Engineering |
| | | | 217 | វិស្វកម្មធនធានរ៉ែ និងការទាញយករ៉ែដែក | Resources Engineering and Extractive Metallurgy |
| | | | 218 | វិស្វកម្មអន្តរវិស័យ | Interdisciplinary Engineering |
| | | | 219 | បច្ចេកវិទ្យាគមនាគមន៍ | Communications Technologies |
| | | | 220 | ផ្នែករឹងកុំព្យូទ័រ | Computer Hardware |
| | | | 221 | ស្ថាបត្យកម្ម | Architecture |
| | | | 222 | សំណង់អគារ | Building |
| | | | 223 | ការអនុវត្ត និងការគ្រប់គ្រងឌីហ្សាញ | Design Practice and Management |
| | | | 224 | ឌីហ្សាញវិស្វកម្ម | Engineering Design |
| | | | 225 | ផែនការទីប្រជុំជន និងតំបន់ | Urban and Regional Planning |
| | | | 226 | បច្ចេកវិទ្យា និងវិស្វកម្មផ្សេងៗទៀត | Other Engineering and Technologies |
| **3** | វិទ្យាសាស្ត្រវេជ្ជសាស្ត្រ និងសុខាភិបាល | Medical and Health Sciences | 301 | វេជ្ជសាស្ត្របឋម | Basic Medicine |
| | | | 302 | វេជ្ជសាស្ត្រគ្លីនិក | Clinical Medicine |
| | | | 303 | វិទ្យាសាស្ត្រសុខាភិបាល | Health Sciences |
| | | | 304 | បច្ចេកវិទ្យាជីវសុខាភិបាល | Health Biotechnology |
| | | | 305 | វិទ្យាសាស្ត្រវេជ្ជសាស្ត្រផ្សេងៗទៀត | Other Medical Sciences |
| **4** | វិទ្យាសាស្ត្រកសិកម្ម | Agricultural Sciences | 401 | កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | Agriculture, Forestry, And Fisheries |
| | | | 402 | វិទ្យាសាស្ត្រសត្វ និង | Animal and Dairy Science |

| | | | | | |
|---|---|---|---|---|---|
| | | | | ទឹកដោះសត្វ | |
| | | | 403 | វិទ្យាសាស្ត្របសុព្យាបាល | Veterinary Science |
| | | | 404 | បច្ចេកវិទ្យាជីវកសិកម្ម | Agricultural Biotechnology |
| | | | 405 | វិទ្យាសាស្ត្រកសិកម្ម ផ្សេងៗទៀត | Other Agricultural Sciences |
| **5** | សង្គម សាស្ត្រ | Social Sciences | 501 | ចិត្តវិទ្យា | Psychology |
| | | | 502 | សេដ្ឋកិច្ច និងពាណិជ្ជកម្ម | Economics and Business |
| | | | 503 | វិទ្យាសាស្ត្រអប់រំ | Educational Sciences |
| | | | 504 | សង្គមវិទ្យា | Sociology |
| | | | 505 | ច្បាប់ | Law |
| | | | 506 | សង្គម និងភូមិសាស្ត្រ សេដ្ឋកិច្ច | Social and Economic Geography |
| | | | 507 | ប្រព័ន្ធផ្សព្វផ្សាយ និង ទំនាក់ទំនង | Media and Communications |
| | | | 508 | វិទ្យាសាស្ត្រសង្គម ផ្សេងៗទៀត | Other Social Sciences |
| **6** | មនុស្សសាស្ត្រ | Humanities | 601 | ប្រវត្តិវិទ្យា និងបុរាណវិទ្យា | History and Archaeology |
| | | | 602 | ភាសា និងអក្សរសាស្ត្រ | Languages and Literature |
| | | | 603 | ទស្សនវិជ្ជា សីលធម៌ និងសាសនា | Philosophy, Ethics and Religion |
| | | | 604 | សិល្បៈ (សិល្បៈ ប្រវត្តិ នៃសិល្បៈ ការសំដែង សិល្បៈ តូរ្យតន្ត្រី) | Art (Arts, History of Arts, Performing Arts, Music) |
| | | | 605 | មនុស្សសាស្ត្រ ផ្សេងៗទៀត | Other Humanities |

## ៧. ចំណាត់ថ្នាក់ វិទ្យាសាស្ត្រនិងបច្ចេកវិទ្យា នៃក្រុម និងថ្នាក់ ទាំងអស់

| ក្រុម (Group) | | | ថ្នាក់ (Class) | | |
|---|---|---|---|---|---|
| លេខកូដ (Code) | ភាសាខ្មែរ | English | លេខកូដ (Code) | ភាសាខ្មែរ | English |
| 101 | វិទ្យាសាស្ត្រគណិតវិទ្យា | Mathematical Sciences | 10101 | គណិតវិទ្យាពិត | Pure Mathematics |
| | | | 10102 | គណិតវិទ្យាអនុវត្តន៍ | Applied Mathematics |
| | | | 10103 | គណិតវិទ្យាចំនួន និងគណិតវិទ្យាគណនា | Numerical and Computational Mathematics |
| | | | 10104 | ស្ថិតិ | Statistics |
| | | | 10105 | គណិតសាស្ត្ររូបវិទ្យា | Mathematical Physics |
| 102 | វិទ្យាសាស្ត្រព័ត៌មាន និងកុំព្យូទ័រ | Computer and Information Sciences | 10201 | សិប្បនិម្មិតឆ្លាតវៃ និងដំណើរការជាមួយរូបភាព | Artificial Intelligence and Image Processing |
| | | | 10202 | ទ្រឹស្តីគណនា និងគណិតសាស្ត្រ | Computation Theory and Mathematics |
| | | | 10203 | កម្មវិធីផ្នែកទន់កុំព្យូទ័រ | Computer Software |
| | | | 10204 | ការកំណត់ទម្រង់ទិន្នន័យ | Data Format |
| | | | 10205 | ប្រព័ន្ធកម្មវិធីចែកចាយព័ត៌មានកុំព្យូទ័រ | Distributed Computing |
| | | | 10206 | ប្រព័ន្ធព័ត៌មាន | Information Systems |
| | | | 10207 | បណ្ណាល័យ និងព័ត៌មានវិទ្យា | Library and Information Studies |
| | | | 10208 | វិទ្យាសាស្ត្រព័ត៌មាន និងកុំព្យូទ័រផ្សេងទៀត | Other Information and Computing Sciences |
| 103 | វិទ្យាសាស្ត្ររូបវិទ្យា | Physical Sciences | 10301 | តារាសាស្ត្រ និងវិទ្យាសាស្ត្រលំហ | Astronomical and Space Sciences |
| | | | 10302 | រូបវិទ្យាអាតូម ម៉ូលេគុល នុយក្លេអ៊ែរ ភាគល្អិត និងប្លាស្មា | Atomic, Molecular, Nuclear, Particle and Plasma Physics |
| | | | 10303 | រូបវិទ្យាក្លាស៊ីក | Classical Physics |

| ក្រុម (Group) | | | ថ្នាក់ (Class) | | |
|---|---|---|---|---|---|
| លេខកូដ (Code) | ភាសាខ្មែរ | English | លេខកូដ (Code) | ភាសាខ្មែរ | English |
| | | | 10304 | រូបវិទ្យាកំណរូបធាតុ | Condensed Matter Physics |
| | | | 10305 | រូបវិទ្យាអុបទិច | Optical Physics |
| | | | 10306 | រូបវិទ្យាកង់ទិច | Quantum Physics |
| | | | 10307 | វិទ្យាសាស្រ្តរូបវិទ្យាផ្សេងទៀត | Other Physical Sciences |
| 104 | វិទ្យាសាស្រ្តគីមីវិទ្យា | Chemical Sciences | 10401 | គីមីវិភាគ | Analytical Chemistry |
| | | | 10402 | គីមីអសរីរាង្គ | Inorganic Chemistry |
| | | | 10403 | គីមីម៉ាក្រូម៉ូលេគុល និងគីមីរូបធាតុសម្ភារៈគីមី | Macromolecular and Materials Chemistry |
| | | | 10404 | គីមីឱសថសាស្រ្ត និងជីវម៉ូលេគុល | Medicinal and Bimolecular Chemistry |
| | | | 10405 | គីមីសរីរាង្គ | Organic Chemistry |
| | | | 10406 | គីមីរូបសាស្រ្ត (រួមទាំង រចនាសម្ព័ន្ធ) | Physical Chemistry (Incl. Structural) |
| | | | 10407 | គីមីទ្រឹស្តី និងគីមីកុំព្យូទ័រ | Theoretical and Computational Chemistry |
| | | | 10408 | វិទ្យាសាស្រ្តគីមីផ្សេងទៀត | Other Chemical Sciences |
| 105 | វិទ្យាសាស្រ្តផែនដីវិទ្យា | Earth Sciences | 10501 | វិទ្យាសាស្រ្តបរិយាកាស | Atmospheric Sciences |
| | | | 10502 | ភូមិសាស្រ្តគីមី | Geochemistry |
| | | | 10503 | ភូគព្ភសាស្រ្ត | Geology |
| | | | 10504 | ភូគព្ភសាស្រ្តរូបវន្ត | Geophysics |
| | | | 10505 | សាគរសាស្រ្ត | Oceanography |
| | | | 10506 | ភូមិសាស្រ្តរូបវន្តនិងភូគព្ភស្រាស្រ្តបរិស្ថាន | Physical Geography and Environmental Geoscience |
| | | | 10507 | វិទ្យាសាស្រ្តផែនដីផ្សេងទៀត | Other Earth Sciences |

| ក្រុម (Group) | | | ថ្នាក់ (Class) | | |
|---|---|---|---|---|---|
| លេខកូដ (Code) | ភាសាខ្មែរ | English | លេខកូដ (Code) | ភាសាខ្មែរ | English |
| 106 | វិទ្យាសាស្ត្រជីវវិទ្យា | Biological Sciences | 10601 | គីមីជីវ និងជីវវិទ្យាកោសិកា | Biochemistry and Cell Biology |
| | | | 10602 | អេកូឡូហ្ស៊ី | Ecology |
| | | | 10603 | ជីវវិទ្យាវិវត្ត | Evolutionary Biology |
| | | | 10604 | ពន្ធុវិទ្យា | Genetics |
| | | | 10605 | អតិសុខុមជីវវិទ្យា | Microbiology |
| | | | 10606 | សរីរវិទ្យា | Physiology |
| | | | 10607 | ជីវវិទ្យារុក្ខជាតិ | Plant Biology |
| | | | 10608 | សត្វវិទ្យា | Zoology |
| | | | 10609 | វិទ្យាសាស្ត្រជីវវិទ្យាផ្សេងទៀត | Other Biological Sciences |
| 107 | វិទ្យាសាស្ត្របរិស្ថាន | Environmental Sciences | 10701 | កម្មវិធីអេកូឡូហ្ស៊ី | Ecological Applications |
| | | | 10702 | វិទ្យាសាស្ត្របរិស្ថាន និងការគ្រប់គ្រងបរិស្ថាន | Environmental Science and Management |
| | | | 10703 | វិទ្យាសាស្ត្រដី | Soil Sciences |
| | | | 10704 | វិទ្យាសាស្ត្របរិស្ថានផ្សេងទៀត | Other Environmental Sciences |
| 108 | វិទ្យាសាស្ត្រធម្មជាតិផ្សេងទៀត | Other Natural Sciences | 10801 | វិទ្យាសាស្ត្រធម្មជាតិផ្សេងទៀត | Other Natural Sciences |
| 201 | វិស្វកម្មសំណង់ស៊ីវិល | Civil Egnineering | 20101 | វិស្វកម្មសំណង់ស៊ីវិល | Civil Engineering |
| 202 | វិស្វកម្មអគ្គិសនីនិងអេឡិចត្រូនិក | Electrical and Electronic Engineering | 20201 | វិស្វកម្មអគ្គិសនីនិងអេឡិចត្រូនិក | Electrical and Electronic Engineering |
| 203 | វិស្វកម្មមេកានិក | Mechanical Engineering | 20301 | វិស្វកម្មមេកានិក | Mechanical Engineering |
| 204 | វិស្វកម្មគីមី | Chemical Engineering | 20401 | វិស្វកម្មគីមី | Chemical Engineering |
| 205 | វិស្វកម្មរូបធាតុ | Materials Engineering | 20501 | វិស្វកម្មរូបធាតុ | Materials Engineering |

| ក្រុម (Group) | | | ថ្នាក់ (Class) | | |
|---|---|---|---|---|---|
| លេខកូដ (Code) | ភាសាខ្មែរ | English | លេខកូដ (Code) | ភាសាខ្មែរ | English |
| 206 | វិស្វកម្មវេជ្ជសាស្ត្រ | Medical Engineering | 20601 | វិស្វកម្មវេជ្ជសាស្ត្រ | Medical Engineering |
| 207 | វិស្វកម្មបរិស្ថាន | Environmental Engineering | 20701 | វិស្វកម្មបរិស្ថាន | Environmental Engineering |
| 208 | វិស្វកម្មអវកាស | Aerospace Engineering | 20801 | វិស្វកម្មអវកាស | Aerospace Engineering |
| 209 | វិស្វកម្មយានយន្ត | Automotive Engineering | 20901 | វិស្វកម្មយានយន្ត | Automotive Engineering |
| 210 | វិស្វកម្មជីវវេជ្ជសាស្ត្រ | Biomedical Engineering | 21001 | វិស្វកម្មជីវវេជ្ជសាស្ត្រ | Biomedical Engineering |
| 211 | វិស្វកម្មចំណីអាហារ | Food Engineering | 21101 | វិស្វកម្មចំណីអាហារ | Food Engineering |
| 212 | វិស្វកម្មមាត្រសាស្ត្រ | Geomantic Engineering | 21201 | វិស្វកម្មមាត្រសាស្ត្រ | Geomantic Engineering |
| 213 | វិស្វកម្មកម្មន្តសាល | Manufacturing Engineering | 21301 | វិស្វកម្មកម្មន្តសាល | Manufacturing Engineering |
| 214 | វិស្វកម្មធនធានរ៉ែ និងការទាញយករ៉ែដែក | Resources Engineering and Extractive Metallurgy | 21401 | វិស្វកម្មធនធានរ៉ែ និងការទាញយករ៉ែដែក | Resources Engineering And Extractive Metallurgy |
| 215 | វិស្វកម្មអន្តរវិស័យ | Interdisciplinary Engineering | 21501 | វិស្វកម្មអន្តរវិស័យ | Interdisciplinary Engineering |
| 216 | បច្ចេកវិទ្យាជីវបរិស្ថាន | Environmental Biotechnology | 21601 | បច្ចេកវិទ្យាជីវបរិស្ថាន | Environmental Biotechnology |
| 217 | បច្ចេកវិទ្យាជីវឧស្សាហកម្ម | Industrial Biotechnology | 21701 | បច្ចេកវិទ្យាជីវឧស្សាហកម្ម | Industrial Biotechnology |
| 218 | បច្ចេកវិទ្យាណាណូ | Nanotechnology | 21801 | បច្ចេកវិទ្យាណាណូ | Nanotechnology |
| 219 | បច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ | Information and Communication Technologies | 21901 | បច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ | Information and Communication Technologies |
| 220 | ផ្នែករឹងកុំព្យូទ័រ | Computer Hardware | 22001 | ផ្នែករឹងកុំព្យូទ័រ | Computer Hardware |

| ក្រុម (Group) | | | ថ្នាក់ (Class) | | |
|---|---|---|---|---|---|
| លេខកូដ (Code) | ភាសាខ្មែរ | English | លេខកូដ (Code) | ភាសាខ្មែរ | English |
| 221 | ស្ថាបត្យកម្ម | Architecture | 22101 | ស្ថាបត្យកម្ម | Architecture |
| 222 | សំណង់អគារ | Building | 22201 | សំណង់អគារ | Building |
| 223 | ការអនុវត្ត និងគ្រប់គ្រងការឌីហ្សាញ | Design Practice and Management | 22301 | ការអនុវត្ត និងគ្រប់គ្រងការឌីហ្សាញ | Design Practice and Management |
| 224 | ឌីហ្សាញ វិស្វកម្ម | Engineering Design | 22401 | ឌីហ្សាញវិស្វកម្ម | Engineering Design |
| 225 | ផែនការអភិវឌ្ឍទីប្រជុំជន និងតំបន់ | Urban and Regional Planning | 22501 | ផែនការអភិវឌ្ឍទីប្រជុំជន និងតំបន់ | Urban and Regional Planning |
| 226 | បច្ចេកវិទ្យា និងវិស្វកម្មផ្សេងៗទៀត | Other Engineering and Technology | 22601 | បច្ចេកវិទ្យា និងវិស្វកម្មផ្សេងទៀត | Other Engineering and Technology |
| 301 | វេជ្ជសាស្ត្របឋម | Basic Medicine | 30101 | វេជ្ជសាស្ត្រជីវគីមី និងមេតាបូលីស | Medical Biochemistry and Metabolomics |
| | | | 30102 | ឱសថសាស្ត្រ និងវិទ្យាសាស្ត្រឱសថ | Pharmacology and Pharmaceutical Sciences |
| | | | 30103 | ការសិក្សាពីប្រព័ន្ធភាពស៊ាំ | Immunology |
| | | | 30104 | ប្រសាទសាស្ត្រ | Neurosciences |
| | | | 30105 | កាយវិភាគសាស្ត្រ | Anatomy |
| 302 | វេជ្ជសាស្ត្រ គ្លីនិក | Clinical Medicine | 30201 | វេជ្ជសាស្ត្រសរសៃឈាមបេះដូង និងគ្រាប់ឈាម | Cardiovascular Medicine and Hematology |
| | | | 30202 | វេជ្ជសាស្ត្រគ្លីនិក | Clinical Sciences |
| | | | 30203 | វេជ្ជសាស្ត្របំពេញ និងជំនួស | Complementary and Alternative Medicine |
| | | | 30204 | ទន្តសាស្ត្រ | Dentistry |
| | | | 30205 | ការសិក្សាពីជំងឺដុះសាច់ និងមហារីក | Oncology and Carcinogenesis |

| ក្រុម (Group) | | | ថ្នាក់ (Class) | | |
|---|---|---|---|---|---|
| លេខកូដ (Code) | ភាសាខ្មែរ | English | លេខកូដ (Code) | ភាសាខ្មែរ | English |
| | | | 30206 | ចក្ខុវិទ្យា និងចក្ខុរោគសាស្ត្រ | Optometry and Ophthalmology |
| 303 | វិទ្យាសាស្ត្រសុខាភិបាល | Health Sciences | 30301 | វិទ្យាសាស្ត្រចលនាមនុស្ស និងកីឡា | Human Movement and Sport Sciences |
| | | | 30302 | ការថែទាំសុខភាព | Nursing |
| | | | 30303 | អាហារូបត្ថម្ភ និងរបបអាហារ | Nutrition and Dietetics |
| | | | 30304 | ជំងឺកុមារ និងវេជ្ជសាស្ត្របន្តពូជ | Pediatrics and Reproductive Medicine |
| | | | 30305 | សុខភាពសាធារណៈ និងសេវាសុខាភិបាល | Public Health and Health Services |
| | | | 30306 | មីក្រុប (អតិសុខុមប្រាណ) | Microbe |
| | | | 30307 | វិទ្យាសាស្ត្រវេជ្ជសាស្ត្រ និងសុខាភិបាលផ្សេងៗទៀត | Other Medical and Health Sciences |
| 304 | បច្ចេកវិទ្យាជីវវេជ្ជសាស្ត្រ | Medical Biotechnology | 30401 | អតិសុខុមវិទ្យា វេជ្ជសាស្ត្រ | Medical Microbiology |
| | | | 30402 | សរីរវិទ្យាវេជ្ជសាស្ត្រ | Medical Physiology |
| | | | 30403 | រោគវិនិច្ឆ័យវេជ្ជសាស្ត្រតាមរូបភាព | Medical Diagnostic Imaging |
| | | | 30404 | ជីវសាស្ត្រគីមី និងគីមីសាស្ត្រ គ្លីនិកក្នុងវេជ្ជសាស្ត្រ | Medical Biochemistry and Clinical Chemistry |
| 305 | វិទ្យាសាស្ត្រវេជ្ជសាស្ត្រផ្សេងៗទៀត | Other Medical Sciences | 30501 | វិទ្យាសាស្ត្រវេជ្ជសាស្ត្រផ្សេងៗទៀត | Other Medical Sciences |

| ក្រុម (Group) | | | ថ្នាក់ (Class) | | |
|---|---|---|---|---|---|
| លេខកូដ (Code) | ភាសាខ្មែរ | English | លេខកូដ (Code) | ភាសាខ្មែរ | English |
| 401 | កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | Agriculture, forestry, and fisheries | 40101 | ការគ្រប់គ្រងកសិកម្ម កសិដ្ឋាន និងដីធ្លី | Agriculture, Land and Farm Management |
| | | | 40102 | វិទ្យាសាស្ត្រជលផល | Fisheries Sciences |
| | | | 40103 | វិទ្យាសាស្ត្រព្រៃឈើ | Forestry Sciences |
| | | | 40104 | វារីវប្បកម្ម | Aquaculture |
| | | | 40105 | ផលិតកម្មដំណាំ និងតិណាហារសត្វ | Crop and Pasture Production |
| 402 | វិទ្យាសាស្ត្រសត្វ និងទឹកដោះ | Animal and dairy science | 40201 | វិទ្យាសាស្ត្រសត្វ និងទឹកដោះ (ផលិតកម្ម) | Animal and Dairy Science (Production) |
| | | | 40202 | ផលិតកម្មសាកវប្បកម្ម (ការដាំដំណាំ) | Horticultural Production (Husbandry) |
| | | | 40203 | ការគ្រប់គ្រងសត្វល្អិត និងជំងឺ | Pest and Disease Management |
| 403 | វិទ្យាសាស្ត្របសុព្យាបាល | Veterinary Science | 40301 | វិទ្យាសាស្ត្របសុព្យាបាល | Veterinary Sciences |
| 404 | បច្ចេកវិទ្យាជីវកសិកម្ម | Agricultural biotechnology | 40401 | បច្ចេកវិទ្យាជីវកសិកម្ម | Agricultural Biotechnology |
| | | | 40402 | បច្ចេកវិទ្យាជីវចំនីអាហារ និងអាហារូបត្ថម្ភ | Food Biotechnology and Nutrition |
| 405 | វិទ្យាសាស្ត្រកសិកម្មផ្សេងៗទៀត | Other agricultural sciences | 40501 | វិទ្យាសាស្ត្រកសិកម្ម និងបសុព្យាបាលដទៃទៀត | Other Agricultural and Veterinary Sciences |
| 501 | ចិត្តវិទ្យា | Psychology | 50101 | ចិត្តវិទ្យា | Psychology |
| | | | 50102 | វិទ្យាសាស្ត្រវិញ្ញាណ | Cognitive Science |
| | | | 50103 | ចិត្តវិទ្យា និងវិទ្យាសាស្ត្រវិញ្ញាណផ្សេងទៀត | Other Psychology and Cognitive Sciences |
| 502 | សេដ្ឋកិច្ច និងពាណិជ្ជកម្ម | Economics And Business | 50201 | ទ្រឹស្ដីសេដ្ឋកិច្ច | Economic Theory |
| | | | 50202 | សេដ្ឋកិច្ចអនុវត្ត | Applied Economics |
| | | | 50203 | សេដ្ឋមាត្រ | Econometrics |

| ក្រុម (Group) | | | ថ្នាក់ (Class) | | |
|---|---|---|---|---|---|
| លេខកូដ (Code) | ភាសាខ្មែរ | English | លេខកូដ (Code) | ភាសាខ្មែរ | English |
| | | | 50204 | សេដ្ឋកិច្ចផ្សេងទៀត | Other Economics |
| | | | 50205 | គណនេយ្យ សវនកម្ម និងគណនេយ្យភាព | Accounting, Auditing and Accountability |
| | | | 50206 | ធនាគារ ហិរញ្ញវត្ថុ និង ការវិនិយោគ | Banking, Finance and Investment |
| | | | 50207 | ការគ្រប់គ្រងធុរកិច្ច | Business Management |
| | | | 50208 | សេវាពាណិជ្ជកម្ម | Commercial Services |
| | | | 50209 | ទីផ្សារ | Marketing |
| | | | 50210 | ទេសចរណ៍ | Tourism |
| | | | 50211 | ការដឹកជញ្ជូន និងសេវាកម្មដឹកទំនិញ | Transportation and Freight Services |
| | | | 50212 | ពាណិជ្ជកម្ម ការគ្រប់គ្រង ទេសចរណ៍ និងសេវាកម្មផ្សេងទៀត | Other Commerce, Management, Tourism and Services |
| 503 | វិទ្យាសាស្ត្រអប់រំ | Educational Sciences | 50301 | ប្រព័ន្ធអប់រំ | Education Systems |
| | | | 50302 | កម្មវិធីសិក្សា និង គរុកោសល្យ | Curriculum and Pedagogy |
| | | | 50303 | ការសិក្សាជំនាញក្នុង វិស័យអប់រំ | Specialist Studies In Education |
| | | | 50304 | ការអប់រំផ្សេងទៀត | Other Education |
| 504 | សង្គមវិទ្យា | Sociology | 50401 | ការងារសង្គម | Social Work |
| | | | 50402 | ប្រធានបទពី សង្គមវិទ្យា | Sociology Topic |
| | | | 50403 | ប្រជាសាស្ត្រ | Demography |
| | | | 50404 | នរវិទ្យា | Anthropology |
| | | | 50405 | ឧក្រិដ្ឋវិទ្យា | Criminology |

| ក្រុម (Group) | | | ថ្នាក់ (Class) | | |
|---|---|---|---|---|---|
| **លេខកូដ (Code)** | **ភាសាខ្មែរ** | **English** | **លេខកូដ (Code)** | **ភាសាខ្មែរ** | **English** |
| 505 | ច្បាប់ | Law | 50501 | គោលនយោបាយនិងរដ្ឋបាលសាធារណៈ | Public Policy and Administration |
| | | | 50502 | វិទ្យាសាស្ត្រនយោបាយ | Political Science |
| 506 | សង្គម និងភូមិសាស្ត្រសេដ្ឋកិច្ច | Social and Economic Geography | 50601 | ភូមិវិទ្យាវប្បធម៌ និងសេដ្ឋកិច្ច | Cultural and Economic Geography |
| | | | 50602 | ទិដ្ឋភាពសង្គម (វិទ្យាសាស្ត្របរិស្ថាន) | Social Aspects (Environment Sciences) |
| | | | 50603 | ភូមិវិទ្យាមនុស្ស | Human Geography |
| 507 | ប្រព័ន្ធផ្សព្វផ្សាយ និងបណ្តាញទំនាក់ទំនង | Media and Communications | 50701 | ប្រព័ន្ធផ្សព្វផ្សាយ និងបណ្តាញទំនាក់ទំនងសង្គម-វប្បធម៌ | Media and Social-Cultural Communication |
| | | | 50702 | វិជ្ជាជីវៈសារព័ត៌មាន និងការសរសេរព័ត៌មាន | Journalism and Professional Writing |
| 508 | វិទ្យាសាស្ត្រសង្គមផ្សេងៗទៀត | Other Social Sciences | 50801 | វិទ្យាសាស្ត្រសង្គមផ្សេងទៀត | Other Social Sciences |
| 601 | ប្រវត្តិសាស្ត្រ និងបុរាណវិទ្យា | History and Archaeology | 60101 | បុរាណវិទ្យា | Archaeology |
| | | | 60102 | ការសិក្សាពីការគ្រប់គ្រងសារមន្ទីរនិងផ្នែកពាក់ព័ន្ធ | Curatorial and Related Studies |
| | | | 60103 | ការសិក្សាប្រវត្តិសាស្ត្រ | Historical Studies |
| | | | 60104 | ប្រវត្តិសាស្ត្រ និងបុរាណវិទ្យាផ្សេងទៀត | Other History and Archaeology |
| 602 | ភាសានិងអក្សរសាស្ត្រ | Languages and Literature | 60201 | ការសិក្សាពីប្រព័ន្ធផ្សព្វផ្សាយ និងគមនាគមន៍ | Communication and Media Studies |
| | | | 60202 | ការសិក្សាវប្បធម៌ | Cultural Studies |
| | | | 60203 | ការសិក្សាភាសា | Language Studies |
| | | | 60204 | ភាសាវិទ្យា | Linguistics |

| ក្រុម (Group) | | | ថ្នាក់ (Class) | | |
|---|---|---|---|---|---|
| លេខកូដ (Code) | ភាសាខ្មែរ | English | លេខកូដ (Code) | ភាសាខ្មែរ | English |
| | | | 60205 | ការសិក្សាអក្សរសាស្ត្រ | Literary Studies |
| | | | 60206 | ភាសា ការទំនាក់ទំនង និងវប្បធម៌ផ្សេងៗទៀត | Other Language, Communication and Culture |
| 603 | ទស្សនវិជ្ជាសីលធម៌ និងសាសនា | Philosophy, Ethics and Religion | 60301 | សីលធម៌អនុវត្ត | Applied Ethics |
| | | | 60302 | ប្រវត្តិសាស្ត្រ និងទស្សនវិជ្ជានៃវិស័យជំនាញ | History and Philosophy of Specific Fields |
| | | | 60303 | ទស្សនវិជ្ជា | Philosophy |
| | | | 60304 | សាសនា និងប្រពៃណីសាសនា | Religion and Religious Traditions |
| | | | 60305 | ការសិក្សាទស្សនវិជ្ជា និងសាសនាដទៃទៀត | Other Philosophy and Religious Studies |
| 604 | សិល្បៈ (ប្រវត្តិនៃសិល្បៈ ការសំដែងសិល្បៈ, ដូរ្យតន្ត្រី) | Art (Arts, History of Arts, Performing Arts, Music) | 60401 | ទ្រឹស្តី និងរិះគន់នានិយមសិល្បៈ | Art Theory and Criticism |
| | | | 60402 | ភាពយន្ត ទូរទស្សន៍និងប្រព័ន្ធផ្សព្វផ្សាយឌីជីថល | Film, Television and Digital Media |
| | | | 60403 | សិល្បៈសំដែង និងការតែងនិពន្ធបែបច្នៃប្រឌិត | Performing Arts and Creative Writing |
| | | | 60404 | ចក្ខុសិល្បៈ និងសិប្បកោសល្យ | Visual Arts and Crafts |
| | | | 60405 | ការសិក្សាផ្សេងៗទៀតនៅក្នុងសិល្បៈនៃការច្នៃប្រឌិត និងសរសេរ | Other Studies In Creative Arts And Writing |
| 605 | មនុស្សសាស្ត្រផ្សេងៗទៀត | Other Humanities | 60501 | ការសិក្សាសង្គមមនុស្សផ្សេងទៀត | Other Humanities |



# ផ្នែក ១

# វិទ្យាសាស្ត្រធម្មជាតិ

# NATURAL SCIENCES

# ផ្នែកទី ១ ៖ វិទ្យាសាស្រ្តធម្មជាតិ

## ១.១. ចំនួនក្រុម ថ្នាក់ និង ថ្នាក់រង នៃ ផ្នែកទី១

| កម្រិត | ច.ជ.វ.ប. |
|---|---|
| ផ្នែក | ១ |
| ក្រុម | ៨ |
| ថ្នាក់ | ៤៨ |
| ថ្នាក់រង | ៣៥៦ |

## ១.២. ចំណាត់ថ្នាក់វិទ្យាសាស្រ្តធម្មជាតិ ជាក្រុម ថ្នាក់ និង ថ្នាក់រង

| ផ្នែក ១ (Division 1) | | | | សេចក្តីអធិប្បាយ | Decription |
|---|---|---|---|---|---|
| ផ្នែក Division | ក្រុម Group | ថ្នាក់ Class | ថ្នាក់រង Sub-Class | ភាសាខ្មែរ | English |
| **1** | | | | **វិទ្យាសាស្រ្តធម្មជាតិ** | **NATURAL SCIENCES** |
| | 101 | | | **វិទ្យាសាស្រ្តគណិតវិទ្យា** | **MATHEMATICAL SCIENCES** |
| | | 10101 | | **គណិតវិទ្យាពិត** | **PURE MATHEMATICS** |
| | | | 1010101 | ពិជគណិត និងទ្រឹស្តីចំនួន | Algebra and Number Theory |
| | | | 1010102 | ធរណីមាត្រពិជគណិត និង ឌីផេរ៉ង់ស្សែល | Algebraic and Differential Geometry |
| | | | 1010103 | ទ្រឹស្តីនៃប្រភេទ ពិជគណិតហ៊ូម៉ូឡូហ្សិក | Category Theory, Homological Algebra |
| | | | 1010104 | គណិតវិទ្យាបន្សំ និងគណិតវិទ្យាញែក (លើកលែងតែ រូបវិទ្យាបន្សំ) | Combinatorics and Discrete Mathematics (excl. Physical Combinatorics) |
| | | | 1010105 | ទ្រឹស្តីតាមក្រុម និងទូទៅ | Group Theory and Generalizations |
| | | | 1010106 | ហាម៉ូនិក និងការវិភាគហ្វួរីយេ | Lie Groups, Harmonic and Fourier Analysis |
| | | | 1010107 | គណិតវិទ្យាឡូស៊ីក ទ្រឹស្តីសំណុំ Lattices និង ពិជគណិតសកល | Mathematical Logic, Set Theory, Lattices and Universal Algebra |
| | | | 1010108 | ពិជគណិតអនុវត្តនិងការវិភាគអនុគមន៍ | Operator Algebras and Functional Analysis |

| ផ្នែក ១ (Division 1) | | | | សេចក្តីអធិប្បាយ | Decription |
|---|---|---|---|---|---|
